# ការសំភាសន៍របស់អ៊ុំស្រី ហ៊ូ វ៉ន

កៈ អ្នកដែរសំភាសន៍គេមាន ជាងស៊ីអ៊ារខៈ អ្នកដែរអោយគេសំភាសន៍ ហ៊ូ វ៉ន

## <u>ការសង្ខេបប្រវត្តិរបស់អ៊ុំស្រី ហ៊ូ វ៉ន</u>

កៈ ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ
ហើយការសំភាសន៍
នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU
ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បី
ទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយ
នឹងប្រវត្តិរបស់ដូចតា ចឹងនៅពេលដែរខ្ញុំបាន
សំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមាន
ឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ
ចឹងតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍
មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ ចា៎!ដាក់សំភាសន៍ទៅយល់ព្រម។

កៈ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍ពូខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ
ហើយថ្ងៃខែដែរខ្ញុំត្រូវសំភាសន៍អ៊ុំមួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី19 ខែ2 ឆ្នាំ2018
ហើយសំភាសន៍នៅភូមិនឹងគេហៅថាភូមិបាល្លាំងថ្មីហ៎អ៊ុំ?

ខៈ នឹងហើយភូមិបាល្លាំងថ្មី។

កៈ ឃុំល្អាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម
ចឹងសំរាប់អ៊ុំមានឈ្មោះពេញនឹងឈ្មោះអីគេដែរទៅអ៊ុំ?

ខៈ មានឈ្មោះយាយ វ៉ន។

កៈ ចុះមានឈ្មោះហៅក្រៅទេអ៊ុំ?

ខៈ អត់មានផង នាមត្រកូលនឹងឈ្មោះហ៊ូ វ៉ន។

កៈ ចឹងឈ្មោះហ្វ៊នហោសអ៊ុំ?

ខៈ ចា៎!នឹងហើយ។

កៈ ប៉ុន្តែឈ្មោះហៅក្រៅនឹងឈ្មោះវ៉ន១១ ចឹងតែម្ដង?

ខៈ នឹងហើយហៅថាវ៉ន នឹងតែម្ដងនឹង។

កៈ ចុះកាលនៅពីក្មេងនឹងមានធ្លាប់មាននរណាហៅអ៊ុំឈ្មោះអីផ្សេងដែរទេអ៊ុំ?

ខៈ អត់មានទេនឹង។

កៈ ចឹងអត់មានទេហោសអ៊ុំ ចុះសព្វថ្ងៃនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំអាយុ59ឆ្នាំ។

កៈ ចុះអ៊ុំកើតនៅថ្ងៃខែឆ្នាំណាដែរអ៊ុំមានចងចាំទេ?

ខៈ អត់ចងចាំផងចៅ។

កៈ ចុះឆ្នាំច័ន្ទគតិអ៊ុំមានឆ្នាំអីគេដែរអ៊ុំ លក្ខណះជូត ឆ្លូវ ខាល ថោះហាសអ៊ុំឆ្នាំអីគេដែរអ៊ុំ?

ខៈ ខ្ញុំឆ្នាំកោ។

កៈ អ៊ូ!ឆ្នាំកោណអ៊ុំ ចឹងអ៊ុំកើតនៅឆ្នាំ1959 អ៊ុំ?

ខៈ ចឹងហោស?

កៈ ថ្ងៃខែក៏អ៊ុំអត់ចងចាំដែរណាអ៊ុំ?

ខៈ អត់ចងចាំទាំងអស់នឹងខ្ញុំចាំតែឆ្នាំកោនឹងមួយនឹង។

កៈ ប៉ុន្តែអ៊ុំកើតនៅណាដែរអ៊ុំ?

ខៈ ខ្ញុំកើតនៅស្វាយទាបស្រុកកំណើតរបស់ខ្ញុំនឹង។

កៈ ប៉ុន្តែភូមិអី ឃុំអីអ៊ុំមានចងចាំទេ?

ខៈ ភូមិស្វាយទាប នៅស្រុកចំការលើ ខេត្តកំពង់ចាម។

កៈ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ ខ្ញុំមានបងប្អូនចំនួន5នាក់។

ក៖ អ៊ុំជាកូនទៅប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំជាកូនពៅគេនឹង។

ក៖ មានស្រីប៉ុន្មាននាក់ ហើយមានប្រុសប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ មានស្រី2នាក់ នឹងប្រុស3នាក់។

ក៖ ប៉ុន្តែពួកគាត់នៅរស់ទាំងអស់គ្នាដែរតើហីអ៊ុំ?

ខ៖ នៅរស់ទាំងអស់គ្នាប៉ុន្តែស្លាប់អស់មួយដែរ នៅសល់តែ4នាក់ទេ។

ក៖ ស្លាប់នឹងបងទីប៉ុន្មានដែរអ៊ុំ?

ខ៖ ស្លាប់នឹងជាកូនទី1នឹង។

ក៖ អូ៎!ចឹងស្លាប់បងទី1ហោសអ៊ុំ ចុះអ៊ុំអាចរៀបរាប់ឈ្មោះបងប្អូនរបស់អ៊ុំបានដែរទេថាពួកគាត់មានឈ្មុឡអីគេខ្លះចឹងហាសអ៊ុំ?

ខ៖ គាត់ឈ្មោះបងយឿន ។

ក៖ នឹងបងទីមួយហោសអ៊ុំ?

ខ៖ នឹងបងទីមួយគាត់បានស្លាប់ហើយ ហើយនៅបងយឿនមួយទៀតច្រឡំមិញនឹងឈ្មោះបងយឹមគាត់ ស្លាប់ នៅបងយឿនគាត់នៅរស់។

ក៖ បងយឿននឹងបងទី2ហីអ៊ុំ?

ខ៖ ចា៎!នឹងហើយបងយឿនបងទី2។

ក៖ ចុះបងទី3វិញអ៊ុំ?

ខ៖ បងទី3ឈ្មោះខ្លាង មួយទៀតស្រី។

ក៖ ចុះស្រីមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ មួយនឹងឈ្មោះហ៊្វ ថាត។

កៈ ចុះបន្ទាប់មកទៀតអ៊ុំ?

ខៈ បន្ទាប់មកនឹងខ្ញុំតែម្តងនឹង។

កៈ អូ៎!អ៊ុំពៅគេនឹង?

ខៈ នឹងហើយខ្ញុំនឹងពៅគេ។

កៈ ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីកាលពីនៅក្មេងៗជាមួយពួកគាត់
លក្ខណៈថាជាលេងឡឹកបាយឡ រឺមួយក៏លេងជាបិទពួនអីចឹងហាសអ៊ុំ?

ខៈ ខ្ញុំចាំដែរកាលពីខ្ញុំនៅតូចៗខ្ញុំមិនដែរបានលេងអីទេពីព្រោះខ្ញុំទៅឃ្វាលគោនឹង។

កៈ អូ៎!អ៊ុំទៅឃ្វាលគោហោសអ៊ុំ?

ខៈ នឹងហើយទៅឃ្វាលគោ
នឹងឃ្វាលក្របីទេហើយចរឹកខ្ញុំដូចប្រុសចឹងស្លៀកតែខោខ្លីទេនឹង ខ្ញុំស្លៀក
តែខោខ្លីនឹងស្លៀកតែដដែរពីបងៗទេនឹងស្លៀកតែត្រឹមៗនឹងទេ។

កៈ អូ៎!ចឹងហោសអ៊ុំ?

ខៈ ហើយខ្មោចតារបស់ខ្ញុំនឹងគាត់ថាអោយយកថ្នាំមួយបាកវីទៅទៅជក់នឹង
ថាកុំអោយម៉ូសខាំពេកចៅ ណាស់។

កៈ អូ៎!អ៊ុំចេះជក់បារីដែរហោសអ៊ុំ?

ខៈ
ចាំ!នឹងហើយរួចទៅគាត់អោយថ្នាំចេះតែបឺតបង្ហុយៗកុំអោយម៉ូសខាំនឹងរហូតដល់ឥឡូវនឹង
ម៉ូសនៅក្នុងព្រៃនៅពេលដែរខ្ញុំឃ្វាលក្របី ឃ្វាលគោនឹងជាមួយតា។

កៈ ហេតុអីបានជាអ៊ុំទៅគេងក្នុងព្រៃចឹង?

ខៈ គេងទៅក្នុងព្រៃទៅឃ្វាលគោ
ឃ្វាលក្របីអង្គុយនៅក្នុងព្រៃនឹងដោយសារតែស្មៅច្រើននឹងហោស។

កៈ ដោយសារតែមានម៉ូសហោស?

ខ៖  ហើយតាៗនឹងគាត់ប្រាប់ខ្ញុំថាអោយជក់បង្គុយម៉ូសចាមកខាំយើងចឹង ខ្ញុំពីដើមនឹងមិនជាអ្នកមាន ប៉ុន្មានទេនឹង មកខ្ញុំទៀតនឹងរឹតតែវេទនាទៀតនឹង។

ក៖  ចឹងហោសអ៊ុំ?

ខ៖  ចា៎!ដល់កូនចៅនឹងកូនរបស់ខ្ញុំនឹងមានទៅដល់10នាក់ហោស។

ក៖  អូ៎!កូនច្រើនដែរអ៊ុំ?

ខ៖  ចា៎!មាន10នាក់ ប៉ុន្តែចិញ្ចឹមតែ3នាក់នឹងសល់ទាំងប៉ុន្មានអោយបងៗជួយចិញ្ចឹមនឹង នឹង2នាក់ទៀតបានទៀខាងប្ដីនឹង។

ក៖  កូនរបស់អ៊ុំហោសអ៊ុំ?

ខ៖  ចា៎!ខ្ញុំលែងគ្នាទៅបានទៅប្ដី2នាក់នឹង នៅនឹងខ្ញុំនឹងមាន4នាក់នឹងសព្វថ្ងៃនឹង។

ក៖  អូ៎!ចឹងអ៊ុំនៅសល់4នាក់ដែរអ៊ុំចិញ្ចឹមហោសអ៊ុំ?

ខ៖  នឹងហើយប៉ុន្តែគេមានប្ដីហើយនឹង ខ្ញុំនៅតែម្នាក់ឯងទេ ហើយកូនៗគេប្រាប់ខ្ញុំថាម៉ែទៅនៅជាមួយខ្ញុំ ទៅប៉ុន្តែខ្ញុំប្រាប់ខ្ញុំប្រាប់ថាមិនអីទេខ្ញុំនៅតែម្នាក់ឯងនឹងទៅ ដើរស៊ីឈ្នួលគេចឹងទៅផ្ទះនឹងក៏គ្មានដែរនឹង មកស្រុកនឹងខ្ញុំជួលដីគេទេ។

ក៖  អូ៎!ចឹងអ៊ុំជួលគេហោសអ៊ុំ?

ខ៖  នឹងហើយគេអាណិតអាសូរខ្ញុំទៅគេយកខ្ញុំតែ5ម៉ឺនទេក្មួយ។

ក៖  ប៉ុន្តែអ៊ុំនៅណាដែរអ៊ុំ?

ខ៖  ខ្ញុំនៅក្នុងខ្ទមជិតនឹង ផ្ទះណុងគេជួលអោយមួយឆ្នាំតែ5ម៉ឺនទេនឹងមកពីគេអាណិតខ្ញុំនឹង ខ្ញុំចេះតែរកស៊ីទៅគេជួលទៅច្រូតស្រូវចឹងទៅ។

ក៖  ចឹងហោសអ៊ុំ?

ខ៖  ហើយបើគេមិនជួលក៏ហីទៅនឹងបានមួយថ្ងៃស៊ីពីរបីថ្ងៃអីចឹងទៅ។

ក៖  ចឹងមានន័យថាអ៊ុំស៊ីឈ្នួលច្រូតស្រូវអោយគេ?

ខ៖ ជួនកាលទៅកើតក៏ទៅៗពេលណាឈឺខ្នង
ឈឺចង្កេះក៏មិនទៅៗនឹងវាវេទនាណាស់ដល់ពេលដែរ
ជំនាន់ពលពតនឹងកាន់តែវេទនាទៀតនឹង នឹងប្រវត្តិរបស់ខ្ញុំនឹង។

ក៖ ចុះអ៊ុំអាចរៀបរាប់ជំនាន់អាពតមកបានទេអ៊ុំ?

ខ៖ ជំនាន់អាពតខ្ញុំនៅរោងចក្រ ខ្ញុំគ្រុនខ្ញុំនៅរោងចក្រនៅកំពង់ចាមយើងនឹងហាស។

ក៖ នៅខេត្តកំពង់ចាមយើងនឹងទេ?

ខ៖ ពេលកាលពីជំនាន់ណុងគ្រុនគេយកទៅអោយពេទ្យពិនិត្យនឹង
ពេទ្យពិនិត្យពេលថ្នាំខ្មែរនឹង។

ក៖ ចុះពេលណុងអ៊ុំមានជំងឺអីគេដែរទៅអ៊ុំ?

ខ៖ អត់មានឈឺអីទេគ្រាន់តែឈឺគ្រុនធម្មតានឹង
អោយពេទ្យពិនិត្យពេទ្យខ្មែរនឹងថាខ្ញុំមានផ្ទៃពោះ
ហើយខ្ញុំៗប្រកែកថាខ្ញុំមានផ្ទៃពោះមកពីណា
ចោទខ្ញុំជាមួយមិត្តគ្មានមិត្តប្រុសណាខ្ញុំមិនដែរស្រលាញ់នរណាទេ។

ក៖ អូ៎!អ៊ុំមិនដែរស្រលាញ់នរណាផងហោសអ៊ុំ?

ខ៖
ចា៎!នឹងហើយដល់ពេលចឹងគេដាក់កំនត់ខ្ញុំថាស្អីៗក៏អោយខ្ញុំនិយាយអោយអស់ដែរថាខ្ញុំបា
នមករដូវ នៅថ្ងៃខែណា
ហើយខ្ញុំបាននិយាយថាមកនៅថ្ងៃខ្ញុំមកហើយនឹងដល់ពេលដែរមកហើយនឹងនៅតែគេមិន
ជឿទៀតនឹង ។

ក៖ អូ៎!អ៊ុំស្គមហោសអ៊ុំ?

ខ៖ នឹងហើយបើស្គមចឹងមានមកពីណាប៉ុន្តែខ្ញុំពោះវារៀងធំហើយធូន់នឹង
ដល់ពេលចឹងគេអោយខ្ញុំដេក ផឹកថ្នាំខ្មែរផងអីផង
សូម្បីតែថ្នាំពេទ្យខ្ញុំឈឺក្បាលផងអីផងនឹងក៏គេមិនអោយខ្ញុំលេបដែរក្លួយគេថាខ្លាច
យើងលេបទំលាក់កូនអីចឹងទៅ។

ក៖ អូ៎!គេគិតចឹងហោសអ៊ុំ?

ខ៖ នឹងហើយគេចេះតែគិតទៅ
ខ្ញុំបាននិយាយថាបើខ្ញុំមានកូនដាក់ខជាមួយមិត្តបងឯងអោយសំលាប់ខ្ញុំ ចុះនឹងណាស់
ហើយបើសិនជាខ្ញុំគ្មានកូនមិត្តបងឯងធ្វើនម៉េចវិញទៅ?

ក៖ ចុះចឹងយ៉ាងម៉េចទៅចឹង?

ខ៖ ដល់ពេលដែរវាយូរៗទៅគេតាមដាន់ជាមួយអ្នកពោះធំហើយខ្ញុំវាគ្មានកូនទេ
ចង់គេស៊ីស្វាយម៉េចក៏
ខ្ញុំមិនចង់និងគេដែរនឹងហើយថីមិនចង់ចុះបើយើងឈឺនឹងរបៀបដូចជាគ្រុនចាញ់ចឹងណាស់
ចឹងបានអីឃ្លានងីនឹងគេបើបាយក៏ស៊ីមិនកើតស្អីនឹងក៏ស៊ីមិនកើតដែរនឹងហាសក្មួយ។

ក៖ បាទត្រូវហើយអ៊ុំ។

ខ៖ ដល់ពេលគេពិនិត្យយូរទៅវាអស់8-9ខែទៅដូចថាវាជាង1-
2ខែទៀតនឹងដូចថាវាមានកូនហើយ ណាស់ចុះបើយើងមិនឃើញនឹងកើតផងនឹង។

ក៖ វា10ខែជាងហើយមិនមានអីទេនឹង?

ខ៖ ចុះបើយើងឈ្នះគេក៏មិនដឹងថាធ្វើម៉េចដែរ
ប៉ុន្តែគ្រាន់តែថាជីវិតរបស់យើងនៅរស់វាមិនបានស្លាប់នឹង ណាស់
ចុះបើខ្ញុំធ្វើអីមិនល្អគឺចីវិតរបស់ខ្ញុំនឹងបានស្លាប់បាត់ទៅហើយនឹង។

ក៖ នឹងហើយត្រូវអ៊ុំ។

ខ៖ វាធ្វើបាបខ្ញុំដាកើទារុណកម្មសូម្បីតែថ្នាំមួយគ្រាប់ទៅពីរគ្រាប់ក៏មិនអោយលេបដែរនឹង
វាធ្វើបាបដល់ប៉ុណ្ណឹង។

ក៖ ប៉ុន្តែពេលណុងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ពេលណុងយើងអាយុ15-16ឆ្នាំទេនឹងនៅឆ្នាំ1977ម៉េចគេទេនោះ។

ក៖ អូ៎!នៅឆ្នាំ1977ហោសអ៊ុំ?

ខ៖ ចា៎!នឹងហើយសូម្បីតែឪពុកម្តាយក៏មិនហ៊ានយកកូនមកដេកនៅជាមួយដែរ
ចុះពេលណុងឪពុកម្តាយ ក៏នៅផ្សេងយើងក៏នៅផ្សេងនៅដោយខ្លួន
ហើយឪពុកម្តាយរបស់ខ្ញុំនឹងគេលុតដំ។

កៈ គេលុតដំយ៉ាងម៉េចទៅអ៊ុំ?

ខៈ គេអោយតៅស្ទូងស្រែ
ហោសគេអោយខ្ញុំមកស្រែវិញនឹងមិត្តនារីឯងទៅស្រែវិញទៅស្ទូង
ដល់ពេលដែរទៅស្ទូងក្អួយអើយអាទឹកត្រឹមចង្កេះហើយវា
ចុះពេលទឹកលិចដល់ត្រឹមច្រមុះហើយស្ទូងអី នឹងកើតទៅ។

កៈ អ៊្ហូ!ចឹងហោសអ៊ុំ?

ខៈ ដកកណ្តាប់ស្រែយើងធម្មតាអ្នកស្រែយើងអស់ហើយមួយថ្ងៃពីរបីផ្លូន
សព្វថ្ងៃក៏ចឹងដែរពីដើមក៏មាន ចឹងដែរទោះមានកំលាំងយ៉ាងណាក៏ដោយនឹង
រួចដល់ជំនាន់ណុងទៀតក្អួយអើយធ្វើបបរមួយខ្ទះអីនឹង ស៊ីគ្នាជាង10នាក់ចឹង
មិនដឹងជាទៅខ្ញុំថាខ្ញុំមិនរស់ផងនឹងជីវិតរបស់ខ្ញុំនឹងដូចថាមិនដឹងជាយ៉ាងម៉េចទេ
មិនស្គាល់ជាតិបាយទេនឹង។

កៈ អ៊្ហូ!ចឹងហូបតែបបរទៅអ៊ុំ?

ខៈ
នឹងហើយដល់ពេលសព្វថ្ងៃទៅវាបានសង្គមគេកសាងទៅគេវែដាច់ចឹងទៅខ្ញុំបានរស់ឡើងវិញចឹងទៅ
ខ្ញុំបានរស់ដល់សព្វថ្ងៃនឹងខ្វ។មានប្តីមានកូនរស់ដល់សព្វថ្ងៃនឹងដល់ពេលដែរដល់ចាស់ទៅ
ថាអោយ ស្រណុកសុខសប្បាយទៅណាស់វាកាន់តែមិនស្រនុកទៀត។

កៈ នៅតែពិបាកទៀតហោសអ៊ុំ?

ខៈ
នឹងហើយវារឹតតែវេទនាទៅនឹងពឹងតែកូនម៉េចថាកូនវាមានដែរមិនថាមិនមានទេប៉ុន្តែកូននឹងវាចង់ វេទនាជាងខ្ញុំម្នាក់ឯងទៅទៀតនឹង។

កៈ ចឹងកូនអ៊ុំយ៉ាប់ដែរហោសអ៊ុំ?

ខៈ ចា៎!នឹងនិយាយចេះទៅគ្នារកព្រឹកច្រកល្ងាច
រកល្ងាចច្រកព្រឹកវិញនឹងណាមកអោយម៉ែណាដល់ពេល

ចឹងខ្ញុំប្រាប់ថាអត់អីទេអោយតែកូនបានស៊ីម៉ែអត់ស៊ីអត់ចុះណាស់នរណារកបានក៏បានទៅនរណារកមិន បានទេក៏ទៅវត្តលោកខ្លះអីខ្លះទៅណាស់។

កៈ អូ៎!ចឹងហោសអ៊ុំ?

ខៈ ខ្ញុំនិយាយតាមត្រង់តែម្តងនឹង។

កៈ បាទត្រូវហើយអ៊ុំ។

ខៈ
បើថាយ៉ាងម៉េចៗខ្ញុំទៅវត្តលោកទៅសុំបាយទឹកវាមួយពេលអីទៅវាមិនអត់ទេណាស់បានអាចរស់ បានមិនអីទេ ដល់ពេលចឹងវាគ្មានលទ្ធភាពណាទេខ្ញុំនឹង។

កៈ ចុះកាលពីជំនាន់ពលពតនឹងគេជំលាសអ៊ុំទៅណាទៅអ៊ុំ?

ខៈ
គេជំលាសទៅកាត់ដេរណាទៅកាត់ដេរដូចអ្វីដែរខ្ញុំនិយាយម៉េញនឹងអោយទៅភ្នំពេញដល់ពេលមិន
ទាន់បានកាត់ដេរផងគេថាអូមិត្តនារីឯងទៅរៀបមនុស្សដាក់ក្នុងរទេះភ្លើងហោស។

កៈ ចឹងអោយអ៊ុំទៅរៀបមនុស្សវិញមិនមែនអោយទៅកាត់ដេរទេ?

ខៈ
នឹងហើយដល់ពេលដែរខ្ញុំរៀបបានតែមួយថ្ងៃនឹងគេវៃគ្នានឹងទៀតនឹងគេថាអូមិត្តនារីអើយគេវៃគ្នាខ្លាំង ណាស់ខ្ញុំដើររត់ទៅ
ដល់ពេលដែររត់ទៅគេថាអូជិះរទេះភ្លើងបកមកជិះរទេះភ្លើងវិញនឹង។

កៈ អូ៎!កាលពីជំនាន់ណុងមានរទេះភ្លើងហោសអ៊ុំ?

ខៈ នឹងហើយគេជិះរទេះភ្លើង
បើរទេះភ្លើងនឹងគ្រាន់តែទៅប្រឆេះចោលនឹងចុះបើត្រកុងគេនឹងរត់បាត់
ដែរនឹងស្រាប់តែមានឡានមួយមកគេជិះហើយគេនិយាយថានាំគ្នារត់ទៅតិចមានអសន្ទៗនឹង។

កៈ ចុះអ៊ុំធ្វើម៉េចទៅចឹង?

ខ៖
ខ្ញុំនឹងគេបាននាំគ្នារត់ទៅៗមិនដឹងថារត់ទៅណាទៅណីទេនឹងរហូតដល់ភ្នំជ្រាវអូរ៉ាល់ហោស។

ក៖ អូ៎!ឆ្ងាយអុំ?

ខ៖ នឹងហើយដល់ពេលដែរទៅដល់ភ្នំជ្រាវអូរ៉ាល់នឹងគេមានមេគេទៀតនឹងណាស់ មានមេកុហកទៀតនឹងណាស់ថាអ្នកបងប្អូនប៉ុន្មាននាក់នឹងគេចែកផ្ទះចែកសំបែងអោយទៅឡើងលើភ្នំទៅប៉ុន្មានជាន់ទៅដល់ហើយនឹងគេចែកដីអីអោយនៅណុង ប៉ុន្តែតាមការពិតនឹងគេកុហកយើងអោយ ឡើងលើភ្នំអោយស្លាប់នឹង។

ក៖ អូ៎!ចឹងគេយកយើងទៅសំលាប់នៅលើភ្នំនឹងហោសអុំ?

ខ៖ នឹងហើយគេយកយើងទៅសំលាប់យើងនៅលើភ្នំនឹង គេមិនសំលាប់ទេគេចេះតែអោយយើងដើរទៅ ដើរទាំងអត់បាយអត់ទឹកចឹងទៅ។

ក៖ ដើររហូតទាល់តែអត់បាយនឹងអត់ទឹកទាល់តែស្លាប់ទៅ?

ខ៖
នឹងហើយបើខ្ញុំថ្នាក់មែនទែនខ្ញុំស្រែកទឹកពេកនោមផឹកខ្លួនឯងហាសចុះបើវាខាស់បំពង់កនឹងហើយ ពួកខ្ញុំមានគ្នាជាង10នាក់ថាបើស្លាប់ក៏ស្លាប់ទៅនាំគ្នាបកក្រោយវិញចុះ។

ក៖ ចឹងគ្នាអុំបានបកក្រោយវិញទៅ?

ខ៖
នឹងហើយមិនបាច់រកផ្ទះរកសំបែងណាទេបើយើងក្រនឹងយ៉ាងម៉េចៗបកទៅស្រុកភូមិវិញនឹង ចុះមិនដឹងថាត្រើយនៅណាកោះនៅណាបើវាមិនស្គាល់ទៅហើយនឹង។

ក៖ ចុះដើរទៅប៉ុន្មានខែបានដើរទៅដល់ភ្នំអូរ៉ាល់នឹងទៅអុំ?

ខ៖ ទៅប្រហែលជាមួយខែជាងដែរនឹងហាស។

ក៖ ចឹងយើងដើររហូត?

ខ៖ មួយខែជាងនឹងយើងដើររហូតនឹងដើរវេទនារហូតនឹង។

ក៖ ចុះបាយម្ហូបយើងយ៉ាងម៉េចទៅអុំ?

ខ៖ តាមផ្លូវតាមប្រជាជនយើងរត់ទៅភូមិនឹងអូភូមិនឹងគេរត់អស់ចឹងទៅ
ទុកនៅតែស្រូវនៅតែអង្ករនឹង
នាំគ្នាយកស្រូវនឹងកើបមកជាន់នឹងក្បៀងបុកនឹងក្បៀងអីចឹងទៅណាស់
វែអាត្បាល់គេវែចឹងទៅចឹងនាំ គ្នាតែយកទៅដាំបាយហូបចឹងទៅ។

ក៖ អូ៎!គេធ្វើចឹងហោសអ៊ុំ?

ខ៖ នឹងហើយអ្នកគេមិនទាន់បានសុំសិល្ប៍ទៅគេវៃមាន់មួយទាមួយចឹងទៅណាស់
ហូបនៅនឹងទៅក៏ដើរទៅទៀតទៅនឹង
ដល់ពេលដែរទៅដល់ភូមិមួយទៀតនឹងស្ងាត់មនុស្សមួយទៀត ហើយនឹង។

ក៖ ចឹងដើរគ្រប់ភូមិហោសអ៊ុំ?

ខ៖
នឹងហើយចុះជំនាន់ណុងចេះតែដើរទៅដើរនឹងមិនដឹងថាដើរទៅណាគោលដៅចេះតែរត់ទៅនឹង
មិនដឹងគោលដៅចេះវានៅសុទ្ធតែក្មេងៗនឹងណាស់ចុះមានចាស់តែពីរបីនាក់នឹងចុះបើចាស់នឹងក៏មិនដឹង ថាដើរទៅណាដែរនឹងខ្លាចតែគេវៃគ្នានឹង។

ក៖ អូ៎!បាទអ៊ុំបាទ?

ខ៖
ចេះតែដើរៗទៅនឹងពេលដែរខ្ញុំមកវិញនឹងម៉ែឪរបស់ខ្ញុំនឹងស្មានតែខ្ញុំស្លាប់បាត់ហើយនឹងដល់ពេល ដែរទទួលបានខ្ញុំមកវិញនឹងម៉ែឪរបស់ខ្ញុំនឹងអរណាស់
ប៉ុណ្ណឹងកូនរបស់អញ់បានរស់វិញហើយនឹង។

ក៖ អូ៎!ចឹងអ៊ុំជួបជុំម្ដាយវិញទៅ?

ខ៖
នឹងហើយបានគាត់ដុតធូបបុណ្យជូនតាអស់ហើយនឹងគាត់ថាគ្មានទេបានរស់រហូតដល់សព្វថ្ងៃនឹង ខ្ញុំវេទនាណាស់ជំនាន់ណុងនឹង ខ្ញុំគិតតែដើរគិតតែរត់គិតតែលូន
ចុះអាពតវាធ្វើបាបរហូតនឹង។

ក៖ ចុះម្ដាយរបស់អ៊ុំពេលណុងគាត់នៅណាដែរអ៊ុំ?

ខ៖
គាត់នៅស្រុកនឹងហើយឪពុករបស់ខ្ញុំនឹងក៏អត់បាយនៅជំនាន់អាពតនឹងដែរគេបង្អត់បាយគាត់ហើមៗ
រោគអីទេគាត់ចេះតែហើមៗទៅគេអោយលេបថ្នាំស្អីគេទេសូន្យនឹងក៏គាត់ស្លាប់បាត់ទៅនឹង។

ក៖ ចឹងឪពុករបស់អ៊ុំស្លាប់ពេលពលពតណុង?

ខ៖
ណុងហើយប៉ុន្តែនៅម្ដាយហើយម្ដាយនឹងគាត់ស្លាប់នៅពេលដែរខ្ញុំបានការហើយរួចរាល់នឹងបានគាត់ ស្លាប់នឹងណាស់គាត់អាយុ72ឆ្នាំបានគាត់ស្លាប់នឹងដែរ
ហើយឪពុកនឹងស្លាប់តាំងពីជំនាន់អាពតនឹង។

ក៖ ចឹងអាពតគេបានយកឪពុករបស់អ៊ុំទៅបង្អត់បាយ?

ខ៖ នឹងហើយគេយកយើងទៅបង្អត់បាយតែម្ដងនឹង។

ក៖ ចឹងរហូតទាល់តែគាត់ស្លាប់នឹង?

ខ៖ នឹងហើយដល់ពេលហូបលែងកើតគាត់ស្លាប់ទៅ
ពីព្រោះតែបបរនឹងវារាវពេកចុះណាមួយនឹង
គ្មានម្ហូបអាហារណាគ្មាននរណាគេមកហូបនៅផ្ទះទេ
គេហូបរួមគ្នាគ្មាននរណាគេងោយហូបឯកជនទេ
ចុះយើងដើរមិនរួចគ្មាននរណាគេខ្វល់ទេហើយគ្មាននរណាគេវេចមកផ្ញើរទេនឹង។

ក៖ គេងោយហូបតិចប៉ុន្តែគេអោយយើងធ្វើការងារច្រើន?

ខ៖ ដល់ពេលចឹងគាត់ដេកអត់បាយស្លាប់ទៅណាស់
ទាល់តែយើងដើររួចទៅឈឺស្កាត់ចឹងទៅ
គេមានកន្លែងមណ្ឌលគេមានកន្លែងពេទ្យស្អីគេនោះ។

ក៖ អូ៎!គេមានកន្លែងអោយដែរហោសអ៊ុំ?

ខ៖
គេអោយដេកចឹងទៅពេលដែរដេកនឹងគ្មានទាំងថ្នាំអីអោយទៀតនឹងណាស់ឪពុករបស់ខ្ញុំដេកទាល់តែ ស្លាប់នឹងគេថាគាត់ហើមៗៗអត់បាយអត់ទឹកនឹងវាហូបមិនឆ្អែតនឹង។

ក៖ ចឹងទេហោសអ៊ុំ?

ខ៖ នឹងហើយវេទនាណាស់ក្មួយអើយ។

ក៖ ចុះពេលដែរដាច់ជំនាន់ពលពតនឹងអ៊ុំមានការលំបាកអីផ្សេងទេអ៊ុំ?

ខ៖
ពេលដែរដាច់ជំនាន់ពលពតចឹងទៅគេបានតែប្តីបានតែប្រពន្ធបានរកស៊ីបានតែមួយរស់ៗចឹងទៅ ណាស់ទើបតែខ្ញុំវេទនាពេលដែរខ្ញុំចាស់ទៅនឹងទេ
ចាំបានមួយរស់ៗនឹងកេនឹងឯងដែរផ្ទះសំបែងក៏គ្មាននឹង គេដែរនឹង។

ក៖ ប៉ុន្តែពេលណុងអ៊ុំរៀបអាពាហ៍ពិពាហ៍ហើយហើយមែនទេអ៊ុំ?

ខ៖ ថាម៉េចដែរ?

ក៖ ពេលដែរដាច់ពលពតហើយនឹងអ៊ុំបានរៀបអាពាហ៍ពិពាហ៍ហើយហើយណាអ៊ុំ?

ខ៖ ពេលដែរដាច់ហើយបានខ្ញុំរៀបនឹង។

ក៖ ចុះអ៊ុំរៀបនៅឆ្នាំណាដែរអ៊ុំ?

ខ៖
អត់ចាំទៀតនឹងហាសមីបងចុះកូនរបស់ខ្ញុំមីបងនឹងឆ្នាំរកាភ្លេចថាអាយុសាមប៉ុន្មានទេនឹង។

ក៖ ខ្ញុំមិនស្គាល់ផងនឹងឆ្នាំខ្មែរនឹង?

ខ៖
ដូចជាសែជាងហើយមើលទៅនឹងឆ្នាំខ្មែរយ៉ាប់ដែរនឹងខ្ញុំមិនសូវចាំឆ្នាំកូនទេទាល់តែបងខ្ញុំបានចាំ។

ក៖ ប៉ុន្តែពេលដែរចូលឆ្នាំកៅជាងអីមានការលំបាកអីទេអ៊ុំ?

ខ៖ ការលំបាកវេទនាមួយចប់នឹងក្មួយអើយ ប្ដីលែងចឹងទៅខ្ញុំលក់អស់ហើយគ្មានសល់អីទេ។

ក៖ ហេតុអីបានជាប្ដីរបស់អ៊ុំលែងអ៊ុំដែរទៅ?

ខ៖ ចា៎ៗ!ថាម៉េចដែរក្មួយ?

ក៖ ហេតុអិបានជាប្ដីរបស់អ៊ុំនឹងលែងគ្នាជាមួយនឹងអ៊ុំដែរ?

ខ៖ ចុះពីព្រោះតែយើងចាស់ហើយនឹងហើយគេក្មេងនឹងហើយក៏លែងគ្នាទៅណាស់។

ក៖ អូ៎!ចឹងទេហោសអ៊ុំ?

ខ៖ ហើយខ្ញុំចេះតែដឹកដៃចិញ្ចឹមកូនៗអោយបានធំៗដូចសព្វថ្ងៃនឹងទៅណាស់ រៀបចំកូនចៅអស់ចឹងទៅ សព្វថ្ងៃនឹងនៅតែម្នាក់ឯងចឹងទៅណាស់។

ក៖ អ៊ុំកាលពីក្មេងអ៊ុំចូលចិត្តលេងអីគេជាមួយបងប្អូនរបស់អ៊ុំអត់?

ខ៖ ហាស?

ក៖ កាលពីក្មេងនឹងអ៊ុំចូលចិត្តលេងអីគេជាមួយបងប្អូនរបស់អ៊ុំអត់?

ខ៖ ពីក្មេងនឹងគ្មានបានលេងអីនឹងបើពីក្មេងនឹងខ្ញុំចូលជំនាន់អាពតដែរហើយនឹង តិចៗវាគ្មានផលវិបាកអី លេងសោះនឹង អូលេងលេងអាសុខឡាបងជាប់គ្នានឹង ធ្លាប់លេងទាញស្អីទេ។

ក៖ ទាញព្រាតមែនអ៊ុំ?

ខ៖ ទាញព្រាតអីណែទាញមួយម្ដងៗដាច់នឹងលាក់កន្សែងឆ្មាខាំកែងនឹងលេង លេងច្បាប់បុរាណតាម ចាស់ៗអីចឹងទៅ ជូនលេងបិទពួនអីចឹងទៅណាស់។

ក៖ នឹងលេងល្បែងប្រជាប្រិយ៍ហើយណាអ៊ុំ?

ខ៖ ចា៎!លេងបិទពួនអីចឹងទៅណាស់ ពេលក្មេងៗនឹងចូលចិត្តលេងចឹងហាស។

ក៖ អូ៎!ចឹងអ៊ុំចូលចិត្តលេងច្រើនដែរហោសអ៊ុំ?

ខ៖ ចា៎!នឹងហើយចូលចិត្តលេងនឹងដល់ពេលដែររៀងចាស់តិចនឹងក៏រៀងខឹលតិចដែរនឹង។

កៈ អ៎ូ!ខឹលយ៉ាងម៉េចទៅអ៊ុំ?

ខៈ អោយតែមុនចូលឆ្នាំនឹងប្រហែលជាមុន4-10អីនឹងខ្ញុំចេះតែនាំក្មេងៗលេងអាយើងបោះឈូងអីចឹង ណាស់។

កៈ លក្ខណៈរាំវែកអីចឹងទៅហោសអ៊ុំ?

ខៈ ក្មេងៗនាំគ្នាអៀនអ្នកខ្លះក៏មិនចេះច្រៀងទៅ ខ្ញុំសំលេងមិនបានមែនប៉ុន្តែចេះតែនាំក្មេងៗច្រៀងទៅ ណាស់អាអើរៗៗចឹងក្មេងៗចេះតែច្រៀងតាមទៅនរណាគេចាញ់ទៅខាងប្រុសច្រៀងម្តងទៅ។

កៈ អ៎ូ!សប្បាយណាស់អ៊ុំ?

ខៈ នឹងហើយកាលណាខាងស្រីចាញ់ចឹងទៅខាងស្រីច្រៀងចឹងទៅណាស់។

កៈ ប៉ុន្តែឥឡូវនឹងជិតដល់ហើយអ៊ុំ?

ខៈ ចា៎!ជិតដល់ហើយនឹងខ្ញុំចូលចិត្តនាំក្មេងៗលេងចឹងណាស់ ប៉ុន្តែឥឡូវនឹងខ្ញុំទៅលែងរួចហើយចៅ អើយយើងគ្មានកំលាំងទេយើងចាស់ទៅហើយនឹង។

កៈ យើងចាស់ច្រើនហើយណាអ៊ុំ?

ខៈ ចា៎!នឹងហើយចឹង។

កៈ បាទអ៊ុំត្រូវហើយ។

ខៈ លក្ខណៈសប្បាយអីទៀតវាចាស់ទៅហើយនឹងខ្ញុំទៅលែងរួចហើយនឹង ប៉ុន្តែខ្ញុំឃើញក្មេងៗគេ ចូលិចិត្តណាស់អោយតែក្មេងលេង។

កៈ នឹងហោសអ៊ុំ?

ខៈ សព្វថ្ងៃនឹងរបាំពេលគេលេងនឹងខ្ញុំទៅមើលសឹងតែរាល់យប់នឹង អារបាំស្ទីគេនេះរបាំស្ទីគេក្មេងៗនាំគ្នា រាំរបាំខ្មែរនៅវត្តយើងនឹង។

កៈ បាទអ៊ុំល្អដែរនឹងអ៊ុំ?

ខ៖ ខ្ញុំទៅមើលរាល់យប់នឹងឥឡូវនឹងយប់ថ្ងៃសៅនឹងគេរាំហើយនឹង
អោយតែយប់ថ្ងៃសៅនឹងកាលពីមុន
រាល់យប់នឹងខ្ញុំថ្ងៃណាក៏ខ្ញុំទៅដែរទៅហើយដើរទាំងហ្វូងៗចឹងទៅខ្ញុំចូលចិត្តមើលណាស់។

ក៖ បាទអ៊ុំបាទចឹង?

ខ៖ ចុះវាសប្បាយហោស។

ក៖ ចុះបងប្អូនរបស់អ៊ុំនឹងសព្វថ្ងៃពួកគាត់រស់នៅណាដែរ?

ខ៖ នៅឆ្ងាយៗណាស់ក្មួយខ្លះទៅនៅស្ទឹងត្រែងទៅ អ្នកខ្លះនៅរតនះគិរីទៅ។

ក៖ អូ៎!បានឆ្ងាយៗណាអ៊ុំ?

ខ៖ ចា៎!ឆ្ងាយដែរនឹងណាស់

ក៖ ប៉ុន្តែពួកគាត់ធ្វើអីគេខ្លះនៅណុងដែរអ៊ុំ?

ខ៖
ធ្វើស្រែចំការនឹងប៉ុន្តែខ្ញុំជិត20ឆ្នាំមិនដែរបានទៅលេងបងប្អូនទេពីព្រោះខ្ញុំវាក្រវាមិនមានលុយទេនឹង គ្មានលុយទៅមកទេចឹងខ្ញុំមិនសូវដឹងទេនឹង។

ក៖ អូ៎!ចឹងហោសអ៊ុំ?

ខ៖
សូម្បីតែទូរស័ព្ទនឹងក៏គ្មានប្រើនឹងគេដែរនឹងមិនដឹងថាជាលេខប៉ុន្មានអីប៉ុន្មានដែរចេះតែហីទៅហីមក នឹងចឹងអត់ទៅ។

ក៖ អូ៎!បាទអ៊ុំ?

ខ៖ នឹងវាចាស់តែខ្លួននឹងលែងគិតហើយសព្វថ្ងៃនឹង។

ក៖ ចុះឪពុករបស់អ៊ុំនឹងឈ្មោះអីគេដែរអ៊ុំ?

ខ៖ គាត់ឈ្មោះហ៊ូនឹងហើយ។

ក៖ ប៉ុន្តែឈ្មោះអីគេហ៊ូដែរអ៊ុំ?

ខ៖ គាត់ឈ្មោះអ៊ឹម ហ៊ូ នឹង។

ក៖ ចុះគាត់អាយុប៉ុន្មានដែរអ៊ុំមានដឹងទេអ៊ុំ?

ខ៖ គាត់ស្លាប់នឹងអាយុ72ឆ្នាំ។

ក៖ ប៉ុន្តែគាត់ស្លាប់ប៉ុន្មានឆ្នាំដែរហើយអ៊ុំ?

ខ៖ ហ៉ោ!ដូចជាមិនមែន72ឆ្នាំទេហី
គាត់ស្លាប់អាយុ72ឆ្នាំចឹងហើយបើខ្មោចម៉ែរបស់ខ្ញុំរស់បានប៉ុន្មានឆ្នាំ
នឹងពេលដែរឪពុកខ្ញុំស្លាប់នឹងម៉ែរបស់ខ្ញុំនឹងអាយុ72ឆ្នាំវិញ។

ក៖ ប៉ុន្តែគាត់ស្លាប់នៅពលពតណាអ៊ុំ?

ខ៖ ចា៎!ស្លាប់នៅពលពតនឹង។

ក៖ ចឹងបើគិតដល់ឥឡូវនឹងគាត់ប្រហែលជាអាយុ120ឆ្នាំអីហើយណាអ៊ុំ?

ខ៖ ចា៎!ប៉ុណ្ណឹងឯងប្រហែល។

ក៖ ចុះគាត់កើតនៅណាដែរអ៊ុំ?

ខ៖ ស្រុកកំណើតគាត់នឹងនៅស្វាយទាបនឹងដែរ។

ក៖ គាត់នៅស្វាយទាបដែរហោសអ៊ុំ ចុះម្តាយរបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ គាត់ឈ្មោះពេជ្រ ខុន។

ក៖ ប៉ុន្តែយាយហើយនឹងតាខុសគ្នាប៉ុន្មានឆ្នាំដែរទៅអ៊ុំ?

ខ៖ ខ្ញុំមិនដឹងអាយុគាត់ទៀតនឹងហាស។

ក៖ ប៉ុន្តែដឹងតែប្អូនតាពីរបីឆ្នាំនឹង?

ខ៖ ចា៎!នឹងហើយប្អូនប៉ុណ្ណឹង អូប្អូន10ឆ្នាំហោស។

ក៖ អូ៎!ចឹងប្អូនតា10ឆ្នាំហោសអ៊ុំ?

ខ៖ នឹងហើយពីព្រោះតាអាយុ82ឆ្នាំយាយអាយុ72ឆ្នាំប្អូន10ឆ្នាំនឹងហើយ។

កៈ ចឹងមានន័យថាយាយប្រហែលជាអាយុមួយរយឆ្នាំជាងហើយនឹង?

ខៈ នឹងហើយគាត់អាយុមួយរយឆ្នាំជាងនឹងប៉ុណ្ណឹងយាយស្លាប់យូរដែរហើយនឹង។

កៈ ប៉ុន្តែយាយកើតនៅណាដែរទៅ?

ខៈ ខ្ញុំស្រុកកំណើតនឹងនៅស្វាយទាបនឹងដែរនឹង។

កៈ ចឹងយាយកើតនៅណុងដែរ?

ខៈ ចា៎!នៅណុង។

កៈ ចុះឪពុករបស់អ៊ុំនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ គាត់ទៅធ្វើតែស្រែដឹកគោអីនឹង និយាយទៅគាត់ធ្វើតែស្រែមួយមុខនឹង។

កៈ អូ៎!បាទអ៊ុំ ចុះគាត់ជាមនុស្សស្លូត រឺមួយក៏កាចដែរអ៊ុំ?

ខៈ គាត់ស្លូតនឹង។

កៈ ចុះម្តាយរបស់អ៊ុំនឹងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ គាត់ក៏ជាអ្នកធ្វើស្រែជាមួយឪពុករបស់ខ្ញុំដែរនឹង
គាត់គ្មានរបររកស៊ីលក់ដូរអីទេនឹងចាស់ៗពីដើមនឹង ធ្វើតែស្រែនឹង។

កៈ ចុះម្តាយរបស់អ៊ុំកាច រឺមួយក៏ស្លូតដែរអ៊ុំ?

ខៈ
ម្តាយរបស់ខ្ញុំស្លូតណាស់ឪពុកម្តាយរបស់ខ្ញុំនឹងគាត់ស្លូតណាស់មិនដែរឈ្លោះប្រកែកទាស់ទែងគ្នា អីទេនឹងណាស់។

កៈ ចុះអ៊ុំមានចងចាំសាច់រឿងអីកាលពីអ៊ុំនៅជាមួយពួកគាត់ដែរទេ?

ខៈ ចងចាំជំនាន់អាពតនឹងឪពុករបស់ខ្ញុំនឹងគាត់ដាក់អន្ទាក់ជ្រូកនឹង។

កៈ ចឹងម៉េចទៅអ៊ុំ?

ខៈ ដល់ពេលដែរដាក់អន្ទាក់ជ្រូកទៅគេអោយរបបមួយកំប៉ុងនឹងគាត់មួយថ្ងៃនឹង
ហើយគាត់យកមក ចិញ្ចឹមបានថៅមួយរស់ហើយបានថៅមួយទៀតនឹង។

កៈ អូ៎!គាត់ឡូយណាស់អ៊ុំ?

ខៈ ហើយគាត់វេទនាជំនាន់អាពតលួចលាក់
គិតទៅខ្ញុំជំនាន់អាពតនឹងគេអោយខ្ញុំដាក់បាយជ្រូក
ដល់ពេលដៃរខ្ញុំហោរពេកខ្ញុំបានលួចអាចុងកន្ទួកក្បាលអង្កាមគេនឹងដាក់ចូលទៅក្នុងកំសៀវ
ទៅបបរ ហើយលួចស៊ីនឹង។

កៈ ចឹងម៉េចទៅអ៊ុំ?

ខៈ
ដល់ពេលចឹងមិត្តនារីម្នាក់គេប្រាប់ខ្ញុំថាហេមិត្តនារីឯងកុំស៊ីអីអានឹងហោសប្រយ័ត្នពោះវៀន
ដុះខ្មែង គេកុហកខ្ញុំមិនហ៊ានស៊ីទេ គេបានស៊ីអស់ទៅទៀតទៅចឹង។

កៈ អ៊ុំចាញ់បោកគេ?

ខៈ នឹងហើយដល់ពេលដៃរខ្ញុំវាហោរហាត់ពេកនឹងសូម្បីតែគល់ចេកនឹងក៏ខ្ញុំស៊ីអស់ដៃរនឹង
តាំងពីទ្រពខ្ញីនិយាយពីផ្អែមនឹងកាលពីជំនាន់ណុងវាផ្អែមណាស់នឹង
ដល់ពេលដៃរវាអត់នឹងស្អីក៏ផ្អែមដៃរ។

កៈ ស្អីក៏ឆ្ងាញ់ដៃរណាអ៊ុំ?

ខៈ គល់ចេកយើងនឹងគាស់យកទៅស្ងោរ គល់ល្ហុងយើងនឹង
និយាយពីស្លវិញលួចស៊ីជំនាន់អាពតនឹង គេដាក់ទាំងធុងៗនឹងលួចបានប៉ុនកដៃនឹងទៅ។

កៈ អូ៎!ចុះពេលណុងគេអត់ដឹងទេហោសអ៊ុំ?

ខៈ មានដឹងណាហើយនិយាយពីស៊ីឆ្ងាញ់ផ្អែមណាស់លោកអើយ
មួយជំនាន់ណុងអោយតែថាបានស៊ី
សឹងតែថាឆ្កែឆ្មាក៏ស៊ីដៃរនឹងហាសនិយាយរួមទៅវាគ្មានអីស៊ីនឹង។

កៈ និយាយរួមទៅសាច់នៅក៏ហូបដៃរមែនទេអ៊ុំ?

ខៈ ចា៎!នឹងហើយសឹងតែមិនស្គាល់រស់ជាតិបាយ
នឹងបបរនឹងយ៉ាងម៉េចទេនឹងប៉ុន្តែមិនដឹងថាបានស៊ីរបៀបណាទៀតនឹង។

កៈ និយាយរួមអោយតែយើងដើរប្រទះឃើញអីយើងហូបទាំងអស់នឹង?

ខ៖ នឹងហើយអោយតែប្រទះនឹងហូបទាំងអស់នឹងចុះវាហេវហើយនឹង។

ក៖ បាទអ៊ុំបាទ?

ខ៖
វាធ្វើបាបយើងអោយតែបបរនឹងលាយជាមួយត្រកួននឹងមួយខ្ទះនឹងឡើងខ្មៅរលំហើយនឹង
សូម្បីតែយើងដើរកាត់គេកំពុងតែវែជួងនឹង
យើងដួសយកអាសំបកពពុះជាប់មាត់ខ្ទះនឹងក៏មិនបានដែរ នឹងវាយ៉ាប់ចឹងទៀតនឹង។

ក៖ អ៊ូ!ដល់ថ្នាក់នឹងផងអ៊ុំ?

ខ៖ អ៊ូ!យកទៅធ្វើជាជីអាចម៍មួយអាទិត្យក៏មានដែរនឹង
អាជាតិបបរនៅជាប់មាត់ខ្ទះនឹងណាស់។

ក៖ ចឹងហោសអ៊ុំ?

ខ៖
ចា៎!វេទនាណាស់គ្រាន់តែលួចទាញមកដើរស៊ីនឹងនៅផ្ទះបាយនឹងក៏គេយកមកធ្វើជាជីដែរនឹ
ង ប៉ុន្តែជីនឹងជីអាចម៍ហាសជីដែរកើបអាចម៍នៅក្នុងព្រៃនឹង
មួយបង្គីៗប៉ុន្មានថ្ងៃចឹងទៅណាស់ធ្វើមួយអាទិត្យនឹង។

ក៖ អ៊ូ!ធ្វើយូរដែរនឹងចឹង?

ខ៖ មួយអាទិត្យនឹងបានរួចអាពពុះបបរនឹង។

ក៖ ដើម្បីយកទៅធ្វើជាជីនឹងហោសអ៊ុំ?

ខ៖ ចា៎!នឹងហើយធ្វើជាជីនឹង
ទោះយើងពពុះបបរនឹងក៏គេដាក់ទោះយើងអោយលើជីធ្វើជាអាចម៍នឹង
អោយទៅមួយអាទិត្យនឹងក៏មានដែរនឹង។

ក៖ អ៊ូ!នឹងវិន័យវា?

ខ៖ នឹងហើយរឿងអាពតប្រវត្តិវាជូរចត់ណាស់។

ក៖ ប៉ុន្តែយើងម៉េចទៅ?

ខ៖ យើងនៅតែរស់បានទៀតនឹង។

ក៖ យើងនៅតែរស់នឹងហោសអ៊ុំ?

ខ៖ តស៊ូណាស់នៅតែចង់រស់ទាល់តែបានទៀតនឹង។

ក៖ ប៉ុន្តែពេលណុងសុខភាពរបស់យើងនឹងវាមិនអីទេហោសអ៊ុំ?

ខ៖ អត់អីទេនឹង។

ក៖ ហូបអីទទេច្រើនប៉ុណ្ណឹងហើយនឹងនៅតែអត់អីទៀតនឹង?

ខ៖ អត់មានបញ្ហាអីទេនឹង ប៉ុន្តែដល់ពេលដៃរធ្លាក់ខ្លួនឈឺដូចខ្ញុំថានឹង
ខ្ញុំឈឺដល់តែគេចោទនឹងជិតស្លាប់ ជិតរស់នឹងគេចោទថាខ្ញុំភើមនឹង។

ក៖ នឹងហោសអ៊ុំ?

ខ៖ នឹងហើយគេចោទថាខ្ញុំមានកូននឹងតាមការពិតនឹងខ្ញុំឈឺនឹង
ឈឺដោយសារតែម្ហូបអាហារយើងវា មិនគ្រប់គ្រាន់នឹងវាវេទនាចឹង។

ក៖ នឹងជាការវេទនារបស់អ៊ុំ?

ខ៖ នឹងហើយឈឺគ្មានបានធ្វើការងារអីទេនឹង ចុះយើងឈឺរាប់ឆ្នាំណោះនឹង។

ក៖ ចុះយាយតាខាងឪពុកនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ ឈ្មោះតាអឹង។

ក៖ ចុះយាយវិញអ៊ុំ?

ខ៖ យាយវិញឈ្មោះយាយពេជ្រ។

ក៖ ចុះគាត់កើតនៅណាអ៊ុំមានដឹងទេ?

ខ៖ គាត់កើតនៅស្រុកអំពិលទ្វា ភូមិអំពិលទ្វា។

ក៖ ទាំងយាយទាំងតាហោសអ៊ុំ?

ខ៖ ចាំ!នឹងហើយនៅណុង។

កៈ ចុះយាយតាខាងម្ដាយវិញ?

ខៈ
នៅខាងណុងដែរនឹងអំពិលទ្វាដែរនៅខាងអំពិលទ្វាប៉ុន្តែខ្ញុំមិនបានស្គាល់ស្រុកអីផងនឹង។

កៈ ប៉ុន្តែពួកគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ ខាងម្ដាយនឹងអត់ស្គាល់ទៀតនឹងហាស ស្គាល់តែខាងឪពុកនឹង
ពីព្រោះពួកគាត់ចាស់ៗអស់ហើយ នឹងខ្ញុំមិនទាន់គាត់ណា។

កៈ ចុះអ៊ុំមកនៅខេត្តនឹងយូរនៅអ៊ុំ?

ខៈ ខ្ញុំមកនៅនឹងទើបតែបាន2ឆ្នាំនឹង។

កៈ ចុះពីមុននឹងអ៊ុំនៅណាដែរទៅចឹងអ៊ុំ?

ខៈ ខ្ញុំដើររសាត់គ្រប់តែកន្លែងនឹង កាលពីមុននឹងខ្ញុំនៅព្រៃទទឹងនោះ។

កៈ ចុះអ៊ុំមានកូនចៅរស់នៅក្រៅប្រទេសទេអ៊ុំ?

ខៈ អត់ផងនឹង។

កៈ ចឹងអត់មានទេណអ៊ុំ?

ខៈ អត់ដែរមានទេនឹង។

កៈ ចុះស្វាមីរបស់អ៊ុំនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខៈ គាត់មានឈ្មោះទ្រី។

កៈ
ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍ថ្ងៃដែរអ៊ុំរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាអីចឹងហាសអ៊ុំ?

ខៈ
ខ្ញុំរៀបនៅឆ្នាំណាទេខ្ញុំភ្លេចដែរហើយប៉ុន្តែនៅជំនាន់ដាច់ជំនាន់ណុងគេចងដៃបាន500នឹង
បាន1000 ដែរហើយនឹង។

កៈ អ៎ូ!ការគេចងលុយដែរហោស?

ខ៖  មានដែរនឹងប៉ុន្តែភាគច្រើនគេចងស្រូវម្នាក់មួយតៅនៅឡើយនឹង គេរាំវៃអោធុងសាំងយើងនឹង អុជជ័រកៅស៊ូប៉ុណ្ណេះនឹងដើម្បីរាំ មួយជំនាន់ការរបស់ខ្ញុំណុងហោស។

ក៖  ប៉ុន្តែដាច់ពលពតប៉ុន្មានឆ្នាំដែរបានជាអ៊ុំការនឹង?

ខ៖  ដាច់ពលពតប្រហែលជា2ឆ្នាំមិនដឹង រឺក៏3ឆ្នាំមិនដឹងទេបានខ្ញុំការនឹង ប្រហែលជា3ឆ្នាំនឹង។

ក៖  ចឹងមានន័យថាខ្វង់ប៉ែតជាងហើយណាអ៊ុំ?

ខ៖  ចាំ!នឹងយាយការស្គរខ្ញុំដែរចឹង។

ក៖  ចឹងហោសអ៊ុំ?

ខ៖  ចាំ!មួយជំនាន់ណុងនៅចំការលើនឹងគេមានមាំសុងអីនឹងគេណា អាជ័រកៅស៊ូជុំទឹកកកប៉ុននេះៗនឹង ដុតធុងសាំងវៃណាស់។

ក៖  ចឹងសប្បាយណាអ៊ុំ?

ខ៖  ចាំ!កាលបីជំនាន់ណុង។

ក៖

ចុះពេលណុងអ៊ុំរៀបអាពាហ៍ពិពាហ៍នឹងអ៊ុំជាអ្នករៀបដោយខ្លួនឯងរឺមួយក៏ឪពុកម្ដាយជាអ្នករៀប អោយដែរអ៊ុំ?

ខ៖  ឪពុកម្ដាយគាត់ជាអ្នករៀបចំអោយនឹង។

ក៖  ប៉ុន្តែពេលណុងដូចជាមានជាជំនូនអត់អ៊ុំ?

ខ៖  អត់ផងគ្រាន់តែផ្គាប់គោមួយ។

ក៖  លក្ខណះផ្គាប់ជាគោមួយតែម្ដងហោសអ៊ុំ?

ខ៖  គោមួយណុងកាប់ស៊ីទាំងអស់គ្នាទៀតនឹងហាសអត់មានផ្គាប់ច្រើនផងនឹង។

ក៖  ចុះអ៊ុំមានចេះអានរឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរអ៊ុំ?

ខ៖ ខ្ញុំចេះបន្តិចៗដែរនឹងខ្ញុំទៅរៀននៅវត្តលោកនឹង។

ក៖ អូ!អ៊ុំរៀនបានថ្នាក់ទីប៉ុន្មានដែរទៅអ៊ុំ?

ខ៖ ពីដើមនឹងគេហៅថាទី12ហ៎។

ក៖ ទី12នឹងស្មើនឹងទៅ1យើងនៅសម័យឥឡូវនឹងហោសអ៊ុំ?

ខ៖ ចា៎!នឹងហើយប៉ុណ្ណឹងហើយមើលដាច់ខ្លះ ហើយមើលមិនដាច់ខ្លះដែរនឹង។

ក៖ អូ!បាទអ៊ុំចឹងមានន័យថាចេះខ្លះអត់ខ្លះ?

ខ៖ ចុះបើម្តាយរបស់ខ្ញុំនឹងគ្មានលុយអោយទៅរៀនផងមិនរៀនវត្តលោក
ហើយលោកវៃអាក្រក់ណាស់ សំរាប់លោកបង្រៀននឹង។

ក៖ ប៉ុន្តែកាលណុងរៀននឹងរៀននៅសាលាណាដែរអ៊ុំ?

ខ៖ រៀននៅសាលានៅស្វាយទាបនឹង។

ក៖ ចុះអ៊ុំមានមិត្តភក្តិដែរធំធាត់មកជាមួយគ្នាដែរទេអ៊ុំ?

ខ៖ ខ្ញុំមិនសូវជាអ្នកដើរលេងទេនឹង មិត្តភក្តិអីមិនដែរមានទេ។

ក៖ អូ!បាទអ៊ុំបាទ?

ខ៖ ហើយម៉ែឪទៅស៊ីឈ្នួលគេចឹងទៅអីទៅ
មិនដែរបានដើរលេងដើរសប្បាយអីនឹងគេទេក្មួយអើយ។

ក៖ ចុះអ៊ុំធ្លាប់ធ្វើការងារអីគេខ្លះដែរនៅក្នុងជីវិតរបស់អ៊ុំដែរអ៊ុំ
តាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ ខ្ញុំគ្មានចេះស្អីទេ ខ្ញុំចេះឧទាហរណ៍ថាលក់ដូរអីតិចតួចទេនឹង
ខ្ញុំដើរស៊ីតែឈ្នួលគេនឹងតាំងពីខ្ញុំក្រមក ខ្ញុំដើរតែចឹងនឹង។

ក៖ អូ!ចឹងហោសអ៊ុំ?

ខ៖ ដើរតែស៊ីឈ្នួលគេធ្វើស្រែចំការគេនឹងមានលក់បបរនឹង។

ក៖ អូ!លក់បបរដែរហោសអ៊ុំ?

ខ៖ ចាំ!នឹងហើយវាចឹងឥឡូវនឹងផ្អាកលក់ហើយក្មួយអើយ
លក់ៗទៅបាត់ដើមបាត់ចុងអស់ហើយនឹង។

ក៖ ចុះអ៊ុំធ្លាប់ទៅធ្វើការនៅវាលស្រែដែរទេអ៊ុំ លក្ខណៈធ្វើស្រែចំការហាស?

ខ៖ ចាំ!ខ្ញុំស៊ីឈ្នួលគេនឹងចឹងមានន័យថាខ្ញុំគ្មានស្រែចំការខ្ញុំដើរស៊ីឈ្នួលគេនឹងច្រូតទៅស្ទូងទៅអោយតែ គេហៅទៅៗនឹងហាស។

ក៖ ចុះអ៊ុំធ្លាប់បើកអាជីវកម្មលក់ដូរអីទេអ៊ុំ?

ខ៖ គ្មានលក់ដូរអីទេសព្វថ្ងៃនឹងប៉ុន្មានខែនេះខ្ញុំលក់បបរនឹង។

ក៖ ចុះអ៊ុំមានធ្លាប់ចិញ្ចឹមសត្វអីទេដូចជាចិញ្ចឹនមាន់ ទា គោ ក្របីអីចឹងហាសអ៊ុំ?

ខ៖ អត់ផងនឹង។

ក៖ ចឹងអត់ដែរទេណាអ៊ុំ?

ខ៖ មាន់ធ្លាប់ដែរនឹង បើគោអីនឹងមិនដែរទេនឹងហាស។

ក៖ អូ៎!ធ្លាប់ហោសអ៊ុំ ប៉ុន្តែនៅតែចិញ្ចឹមអត់អ៊ុំ?

ខ៖ ឥឡូវនឹងឈប់ហើយ។

ក៖ ចឹងឥឡូវនឹងឈប់ហើយណាអ៊ុំ?

ខ៖ គ្មានចិញ្ចឹមទេចៅអើយវាចាស់ហើយនឹង។

ក៖
ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរអីគេខ្លះដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ ផ្លាស់ប្តូរអីចៅ ពេលនៅក្មេងវារៀងគ្រាន់បើ
ដល់ពេលដែរមានកូននឹងចៅទៅវាកាន់តែវេទនាទៅ
វាពិបាកកូនផងណាមួយអាខ្លួនឯងនឹងវាអត់មានទៀតគ្មានសង្ឃឹមនរណាទេកូនអើយ។

ក៖ បាទអ៊ុំចឹង?

ខ៖  ចឹងសុខចិត្តនៅតែម្នាក់ឯងតែម្ដងទៅចឹងនោះ
កូនក៏មិនសង្ឃឹមយើងនឹងក៏មិនសង្ឃឹមគេរកតែខ្លួនឯង
នឹងមិនសឹងទាំងរស់ផងនឹងចឹងនៅតែម្នាក់ឯងតែម្ដងទៅណាស់។

ក៖  ចុះអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរអ៊ុំ?

ខ៖  ចាំ!ខ្ញុំចូលចិត្តតែសំលម្ជូរ នឹងប្រហើរនឹង
កកូរអីតែប៉ុណ្ណឹងទេសំរាប់ឆាអីខ្ញុំមិនសូវជាចូលចិត្តទេនឹង។

ក៖  ចុះអ៊ុំចូលចិត្តបទចំរៀងអីគេដែរអ៊ុំចូលចិត្តច្រៀងហាស?

ខ៖  ចូលចិត្តតែបទប្រជាប្រិយ៍នឹងលក្ខណះបោះឈូងអីចឹងទៅណាស់
ចានឹងរាំវង្សរាំអីទៅចេះដែរពីដើមនឹងសព្វថ្ងៃនឹងក៏ចេះដែរប៉ុន្ដែយើងចាស់ហើយនឹង។

ក៖  ចឹងហោសអ៊ុំ?

ខ៖  ច្រៀងវាមិនកើតខ្លាចគេសើចនឹង កាលពីដើមនឹងមិនបាច់ទេនឹង។

ក៖ ចុះមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ៊ុំនឹងចេះលេងឧបករណ៍ភ្លេងដែរទេអ៊ុំ?

ខ៖  មានតែកូនប្រសារនឹង។

ក៖  គាត់លេងអីគេដែរទៅអ៊ុំ?

ខ៖  គេលេងភ្លេងការនឹង។

ក៖  អូ៎!លេងភ្លេងកាតណោះអ៊ុំ?

ខ៖  ចាំ!នឹងហើយលេងអានឹង។

ក៖
ចុះផ្ទះរបស់អ៊ុំនឹងមានលក្ខណះបែបណាតាំងពីក្មេងរហូតមកដល់ពេលនេះហាសពីក្មេងផ្ទះយ៉ាងម៉េច ហើយឥឡូវនឹងផ្ទះយ៉ាងម៉េចចឹងហាស?

ខ៖
ពីក្មេងផ្ទហានឹងវាបានប្រហែលជា5ម៉ែត្រអីនឹងណាស់មានបណ្ដោយ5នឹងទទឹងមាន4ដែរនឹង។

កៈ អ៊ូ!គួរសមដែរនឹង?

ខៈ ដល់ពេលដែរចាស់ទៅខ្ញុំធ្លាប់ខ្លួនឈឺទៅខ្ញុំក៏លក់អស់ចឹងទៅ
សូម្បីតែដីក៏គ្មានអីក៏គ្មានដែរអីឥឡូវនឹង។

កៈ ចុះផ្ទះឥឡូវនឹងយ៉ាងម៉េចដែរអ៊ុំ?

ខៈ ផ្ទះឥឡូវនឹងរោងតៀមនឹងនឹងមួយគ្រែនឹងក្មួយឯងបានឃើញស្រាប់ហើយណា
ផ្ទះនៅក្រោមដើមស្វាយនឹង។

កៈ បាទអ៊ុំបាទចឹង?

ខៈ នឹងវាចឹងណាស់។

កៈ ចុះមានជំនាញអីគេដែរអ៊ុំគិតថាអ៊ុំចេះស្ទាត់ជំនាញដែរអ៊ុំ?

ខៈ ខ្ញុំចេះដែរប៉ុន្តែគ្រាន់តែថាសព្វថ្ងៃនឹងបើលក់នំក្មេងៗវិញនឹង
ប្រដាប់ក្មេងស៊ីនឹងក៏ចេះដែរប៉ុន្តែ លក្ខណៈថាអត់មានលុយអីចឹងទៅណាស់។

កៈ ចឹងណាអ៊ុំចឹង?

ខៈ បើមានលុយទៅយើងផងអាចលក់បានគ្រាន់តែចិញ្ចឹមជីវិតអីចឹងទៅ
រង់ចាំតែជួលទៅមួយថ្ងៃនឹងទៅ បើគេមិនជួលទេក៏ហីទៅនឹង
ទ្រាំអត់ស៊ីអត់ឃ្លានខ្លះទៅណាស់។

កៈ ចុះចង់និយាយដែរទាក់ទងនឹងអ៊ុំវិញលក្ខណៈបទពិសោធន៍ល្អវិញអ៊ុំ
ចុះអ៊ុំធ្លាប់មានបទពិសោធន៍អី ល្អៗនៅក្នុងជីវិតដែរទេអ៊ុំ?

ខៈ មួយជីវិតនឹងដូចជាគ្មានការសប្បាយអីសោះនឹង។

កៈ ចឹងមានការសប្បាយអីទេ?

ខៈ គ្មានទេនឹងខ្ញុំវេទនាមួយជិវិតនឹងទៅហើយនឹង
ពេលដែរធំដឹងក្តីមកមានប្តីមានប្រពន្ធនឹងធ្លាប់តែមាន
ផលវិបាកនឹងតាំងពីប្តីទីមួយនឹងរហូតដល់ប្តីទាល់តែប្តីទី2នឹងមួយចប់នឹង។

កៈ អ៊ូបាទអ៊ុំ?

ខ៖  និយាយទៅគ្មានការសប្បាយអីទេនឹង។

ក៖  ចុះកាលពីនៅក្មេងៗនឹងហាសអ៊ុំគិតថាពេលដែរធំឡើងនឹងអ៊ុំចង់ធ្វើអីគេដែរទេនឹង?

ខ៖  គ្មានសម័យធ្វើអីទេពីដើមនឹងសម័យតែធ្វើស្រែធ្វើចំការតែមួយមុខនឹង។

ក៖  អ្ហូ!បាទអ៊ុំបាទ?

ខ៖  ពីដើមដូចគ្មានថាទៅខាងណាកាត់ដេរអីអត់ទេនឹង
ចង់បានតែស្រែនឹងតែម្តងនឹងពេលដែរធំដឹងក្តី
មកនឹងអោយតែម៉ែចែកកេរ្ត៍ច្រើននឹងតិចនឹង។

ក៖  អ្ហូ!ចឹងហោសអ៊ុំ?

ខ៖  លក្ខណះថាអញធ្វើស្រែបានតិចមកនឹង ខ្ញុំគ្មានចង់ធ្វើអីក្រៅពីរបរនឹងទៀតទេនឹង។

ក៖
ចុះបើសិនជាចង់អោយអ៊ុំផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗនឹងតើអ៊ុំចង់ផ្តែផ្តាំអីទៅពួកគាត់ដែរទៅអ៊ុំ?

ខ៖  ខ្ញុំចង់ផ្តែផ្តាំនឹងក្មេងៗជំនាន់ក្រោយនឹងអោយចេះរៀនណាប្រឹងអោយ
អោយប្រឹងរៀនកុំអោយល្ងង់ ដូចខ្ញុំនឹង ខ្ញុំនឹងវាគ្មានលុយបង់សាលាដូចគេទេក្មួយអើយ ។

ក៖  បាទអ៊ុំចឹងហោស?

ខ៖  ដល់ពេលក្មេងៗនេះគេអោយបង់បាត់សាលាអត់យកលុយទេ
ហើយដល់ពេលដែរគេមិនយកលុយចឹងទៅប្រឹងឡើងកូនចៅជំនាន់ក្រោយនឹងអោយរៀន
បានចេះដឹង នឹងគេទៅ គេត្រូវការតែងក្សរទេសម័យនេះណោះ
បើយើងមិនចេះអក្សរនឹងក៏មិនអាចធ្វើការងារអីមិន កើតដែរនឹង។

ក៖  បាទល្អចឹងអ៊ុំ?

ខ៖  សម័យណុងកូនចៅក្រោយៗនឹងខំប្រឹងរៀនសូត្រ កុំដើរស៊ីផឹកជក់ម៉ា
កុំអោយប្រព្រឹត្តអោយសោះ នឹងដូចថាធ្វើតែអ៊ុំថានឹង
អោយកាន់តែអំពើល្អកុំអោយកាន់អំពើអាក្រក់នឹង ខ្ញុំសុំតែចឹងទេនឹង។

ក៖ ចុះបើលក្ខណះថាអោយពួកគាត់ជៀងវាងអីគេខ្លះដែរអ៊ុំ?

ខ៖ ចា៎!ជៀសវៀងជាងគេនឹងគ្រឿងញៀននឹង។

ក៖ ចុះមានអីផ្សេងទៅទេអ៊ុំ?

ខ៖ ចឹងមិនចង់អោយវែតប់គ្នានឹង នឹងអំពើហឹង្សានេះមួយទៀតនឹង។

ក៖ ចឹងហោសអ៊ុំ?

ខ៖ នឹងហើយដាក់ប្រពន្ធនឹងដាក់កូនចឹងទៅ
កុំអោយមានអំពើហឹង្សាអោយវាចេះកែប្រែនឹង
ល្អនឹងកុំអោយមានកូនចៅនឹងធ្វើជាចឹងនឹងណា
ថាធ្វើម៉េចអោយវាល្អឡើងនឹងទៅកូនចៅជំនាន់ក្រោយ នឹងក៏នៅជិតគ្នាដែរនឹង។

ក៖ ចុះចឹងមានអីផ្សេងដែរចង់ផ្តែរផ្តាំនឹង។

ខ៖ ចឹងជាចុងក្រោយខ្ញុំអរគុណ។

ក៖
ចឹងមានន័យថាខ្ញុំអរគុណច្រើនអ៊ុំហើយខ្ញុំដាក់សំភាសន៍ផ្តល់ពេលវេលាពីប្រវត្តិរបស់អ៊ុំនឹង
។

ក៖ បាទចឹងជាចុងក្រោយនឹងភ្លេចហើយនឹងអរគុណច្រើនអ៊ុំ៕៕៕